# សុវត្ថិភាពការងារនៅពេលប្រើឧបករណ៍ប្រើដៃ

## 수공구 사용 시 작업 안전

2018-교육미디어-375

### តើ ឧបករណ៍ប្រើដៃ គឺជាអ្វី? '수공구 사용 작업'이란?

• ឧបករណ៍ប្រើដៃគឺជាឧបករណ៍ការងារសាមញ្ញ ដែលអាចប្រើបានយ៉ាងងាយស្រួល ទោះបីជាកម្មករមិនមានជំនាញក្នុងការងារផលិត ជួសជុល ឬថែទាំដោយដៃក៏ដោយ ហើយវាត្រូវបានប្រើស្ទើរគ្រប់ឧស្សាហកម្ម ព្រមទាំងកន្លែងផលិតកម្ម និងសំណង់ផងដែរ។
ការប្រើប្រាស់ ឧបករណ៍ប្រើដៃ ធ្វើឲ្យការងារលឿន និងងាយស្រួល តែទោះជាយ៉ាងនេះក្តី ការប្រើប្រាស់ឧបករណ៍ដែលមិនសមស្របនឹងលក្ខណៈរាងកាយនៃកម្មករ ឬមិនសមស្របនឹងទំហំការងារ ឬក៏ការប្រើប្រាស់វាម្តងហើយម្តងទៀតក្នុងរយៈពេលយូរ អាចធ្វើឲ្យមានបញ្ហារាងកាយមួយចំនួនដូចជា បញ្ហាសាច់ដុំ និងឆ្អឹង។

수공구는 제조업, 건설업뿐만 아니라 거의 모든 업종에 걸쳐 작업자가 제작, 보수, 수리 등의 일을 손으로 할 때 전문성이 없어도 편리하게 사용하는 간단한 작업 도구이다.
수공구를 쓰면 작업을 빠르고 편리하게 할 수 있지만, 작업자의 신체적 특성 또는 작업의 내용에 맞지 않는 수공구를 사용하거나 반복적으로 오래 사용하면 근골격계질환 등의 신체적 질병을 일으키는 원인이 된다.

### ⚠ គ្រោះថ្នាក់ការងារដែលអនុវត្តដោយប្រើឧបករណ៍ប្រើដៃ 수공구 사용 작업의 유해요인

- ធ្វើការងារដដែលៗដោយប្រើឥរិយាបថដដែលៗ
  같은 자세, 같은 작업의 반복
- សីតុណ្ហភាពត្រជាក់ពីកន្លែងធ្វើការត្រជាក់ ឬឧបករណ៍ប្រើដៃដែលត្រជាក់
  추운 작업공간이나 수공구에 의한 차가운 온도
- ឥរិយាបថមិនសមស្របដូចជា មួល ឬបត់កដៃ ឬផ្អៀងទៅក្រោយ
  손목을 비틀거나 굽히고 뒤로 젖히는 등의 부적절한 자세
- ភាពតានតឹងដែលបណ្តាលមកពីការប៉ះរាងកាយនៅពេលឧបករណ៍ប្រើដៃដែលស្រួចសង្កត់ត្រូវ
  날카로운 수공구에 신체가 눌리게 되는 접촉 스트레스
- រំញ័រ និងសម្លេងដែលចេញពីឧបករណ៍
  공구로부터 발생하는 진동과 소음

### ការពិចារណានៅពេលជ្រើសរើសឧបករណ៍ប្រើដៃ 수공구 선택 시 고려사항

**ដង 손잡이**
- រូបរាង 모양
- ប្រវែង និងអង្កត់ផ្ចិត 길이 · 지름
- ដងបន្ថែម 보조손잡이
- វត្ថុធាតុ កន្លែងប៉ះ ។ល។
  재질 · 접촉면적 등

**ភាពញឹកញាប់នៃការប្រើប្រាស់ 사용빈도**
- ពេលប្រើប្រាស់ 사용시간
- រ៉ឺស័រ 스프링 반동장치
- ចំនួននៃការប្រើប្រាស់ឡើងវិញ ។ល។
  반복 사용 정도 등



**កម្មករ 작업자**
- អាយុ 연령
- ភេទ 성별
- ឥរិយាបថការងារ 작업자세
- កម្លាំងសាច់ដុំ 근력
- លក្ខណៈរាងកាយ 신체적 특성 등

**ទម្ងន់ 무게**
- ទម្ងន់នៃឧបករណ៍ 공구 무게
- ទីប្រជុំទម្ងន់ 무게중심 등

**ការពិចារណាផ្សេងទៀត 기타**
- លំនឹង 안정성
- រំញ័រ 진동
- ការពាក់ស្រោមដៃ 장갑 착용
- ភាពចម្រុះនៃការងារ 작업 다양성
- ម៉ោងសម្រាក 휴식시간
- ការបណ្តុះបណ្តាល ។ល។ 교육·훈련등

고용노동부 산업재해예방 안전보건공단

OPEN 출처표시 공공누리 공공저작물 자유이용허락

COMBODIA

## ជ្រើសរើសឧបករណ៍ប្រើដៃដែលត្រឹមត្រូវ 올바른 수공구의 선택

- ជ្រើសរើសឧបករណ៍ប្រើដៃដោយយោងតាមលក្ខណៈនៃការងារ
  작업 특성에 맞는 수공구 선택
- ជ្រើសរើសឧបករណ៍ស្រាលដែលមានរំញ័រតិច
  가볍고 진동이 적은 공구 선택
- ជ្រើសរើសឧបករណ៍ប្រើដៃដែលមានរូបរាងដងត្រូវនឹងទិសធ្វើការរបស់អ្នកប្រើ
  작업 방향과 손잡이 모양이 일치하는 공구 선택
- ជ្រើសរើសឧបករណ៍ដែលមានដងកោង
  손잡이가 꺾인 수공구 선택
- ជ្រើសរើសឧបករណ៍ដែលមានកម្រាស់ និងប្រវែងសមស្រប
  손잡이 굵기 및 길이가 적합한 공구 선택

### ឧបករណ៍ដែលមានកម្រាស់ និងប្រវែងដងសមស្រប
손잡이 굵기 및 길이가 적합한 공구




- ជ្រើសរើសដងដែលមានប្រវែង និងរូបរាងសមស្របនឹងកិច្ចការ និងលក្ខណៈរបស់អ្នកប្រើ
  손잡이 길이, 형태 등이 작업 내용과 작업자 특성에 맞는 공구 선택
- ជ្រើសរើសឧបករណ៍ដែលមានកម្រិតកកិតសមស្របនៅលើដង ប៉ុន្តែមិនសង្កត់លើដៃខ្លាំងពេក
  손잡이에 적절한 마찰이 있고 손이 압박되지 않는 공구 선택
- ជ្រើសរើសឧបករណ៍ដែលគ្មានស្នាមចង្អូរម្រាមដៃលើផ្ទៃដងរបស់វា
  손잡이 표면에 손가락 모양의 홈이 없는 공구 선택
- ជ្រើសរើសឧបករណ៍ដែលមានរ៉ឺស័រនៅលើដងទាំងពីរ
  양쪽 손잡이의 스프링 반동장치 부착 공구 선택
- កែលម្អឥរិយាបថការងារ
  작업자세 개선

### ឧបករណ៍ដែលមានរ៉ឺស័រនៅនឹងដង
손잡이에 스프링 반동장치가 부착된 공구



ផ្តល់ដងកាន់បន្ថែមដើម្បីទប់ស្កាត់ការបត់កដៃ
손목을 굽히지 않도록 보조손잡이 제공

### ផ្លាស់ប្តូរឥរិយាបថការងារ 작업자세 변경



ការងារអង្គុយច្រើន
앉아서 하는 작업

→ ការងារឈរ
서서 하는 작업

### កែតម្រូវកំពស់តុធ្វើការ 작업높이 변경



ការងារឈរ
서서 하는 작업

→ កែតម្រូវទិសផលិតផល ឬបន្ទាបកំពស់តុធ្វើការ
제품의 방향 변경 또는 작업 높이를 낮춤

# ទប់ស្កាត់គ្រោះថ្នាក់លើជណ្តើរ
## 계단에서의 위험 방지

2018-교육미디어-376

### តើ ជណ្តើរ គឺជាអ្វី? '계단'이란?

- ជណ្តើរគឺជាច្រកផ្លូវដែលមានមុំទេរពី 20 ទៅ 45 ដឺក្រេ ដើម្បីភ្ជាប់ជាន់មួយទៅជាន់មួយទៀតនៃអគារមួយ។ ផ្ទៃកទទឹងគឺជាបន្ទះ ឬកន្លែងទ្រជើងរាបស្មើ។ លើសពីនេះទៅទៀតវាត្រូវតែមានសុវត្ថិភាពក្នុងការផ្លាស់ទីលើផ្ទៃរបស់វា។

계단은 높이가 다른 두 바닥면을 연결하기 위하여 일반적으로 20도 초과부터 45도까지의 경사각을 갖는 통로로서 수평부재는 판 모양이나 평면 발판으로 이루어진 것을 말하며 무엇보다도 안전하게 이동할 수 있어야 한다.

### ⚠ កត្តាហានិភ័យធំៗ 주요 위험 요인




ការធ្លាក់ដោយចៃដន្យ
낙하물에 의한 위험




ការបែក
넘어짐에 의한 위험




ការរអិលធ្លាក់
실족에 의한 위험

### ប្រអប់ត្រួតពិនិត្យ | រចនាសម្ព័ន្ធជណ្តើរ (រួមទាំងជណ្តើរបណ្តោះអាសន្ន)
Check Box | 계단의 구조(가설계단 포함)



- H: កំពស់សរុប 계단높이
- g: ទទឹងកាំជណ្តើរ 발판깊이
- e: កំពស់ផុតក្បាលពីលើកាំជណ្តើរ 발판위의 머리공간
- h: កំពស់កាំនីមួយៗ 답단높이
- p: កន្លែងបត់ 계단참
- r: បន្ទះត្រួត 겹침
- a: មុំ [កម្រិតទេរ] 경사각
- L: ទទឹងផ្ទៃ 통로폭
- SL: ផ្ចឹមទ្រជណ្តើរ 경사선









រចនាសម្ព័ន្ធដែលគ្មានហានិភ័យពីការធ្លាក់វត្ថុដូចជាឧបករណ៍ជាដើម
공구 등의 낙하 위험이 없는 구조

## ⚠ ករណីគ្រោះថ្នាក់ 재해사례



- បាត់បង់លំនឹង រួចហើយដួលធ្លាក់នៅពេលដើរចុះជណ្តើរ

  계단에서 내려가다 몸의 중심을 잃고 넘어짐

  នៅពេលចុះជណ្តើរដើម្បីរៀបចំបៀកជញ្ជាំងនៅក្នុងបន្ទប់ម៉ាស៊ីននៅអគាររដ្ឋបាល កម្មករម្នាក់បានបាត់បង់លំនឹង រួចហើយធ្លាក់ពីលើជណ្តើរ។ កម្មករនោះត្រូវរបួសក្បាល ហើយបន្ទាប់មកបានស្លាប់

  아파트 관리동의 기계실 벽체 미장작업 준비를 위해 계단을 내려가던 중 몸의 중심을 잃고 넘어지며 계단을 굴러 머리를 다쳐 사망

## មូលហេតុនៃគ្រោះថ្នាក់ 재해원인

- គ្មានច្រកផ្លូវសុវត្ថិភាព

  안전한 통로 미 설치

  - ក្រណាត់មិនត្បាញ ត្រូវបានដាក់មិនបានជាប់ល្អជាមួយនឹងកាំជណ្តើរនីមួយៗ ហើយវាបានបង្កជាឧបសគ្គ (ធ្វើឲ្យរអិល ឬជំពប់ជើង) ចំពោះច្រកផ្លូវធម្មតា

    부직포를 계단 답단의 굴곡에 맞춰 밀착 되지 않은 상태로 설치하여 정상적인 통행에 방해(미끄러지거나 걸려 넘어짐) 요소로 작용

- ការការពារក្បាលមិនបានគ្រប់គ្រាន់ដោយសារមិនបានពាក់មួកសុវត្ថិភាព

  안전모를 미착용하여 머리 보호 미흡

## វិធានការការពារ 예방대책

- ពង្រឹងច្រកផ្លូវសុវត្ថិភាព

  안전한 통로 확보

  - ត្រូវប្រាកដថា គ្មានហានិភ័យនៃការធ្លាក់ចុះពីជណ្តើរ ឬរអិលលើក្រណាត់មិនត្បាញដែលមានចលនា

    계단통로에 발이 걸려 넘어지거나 부직포의 유동으로 미끄러지는 등의 위험이 없도록 조치

- ពាក់ឧបករណ៍ការពារផ្ទាល់ខ្លួនឲ្យបានហ្មត់ចត់

  개인보호구 착용 철저

  - នៅពេលកម្មករនៅការដ្ឋានសំណង់ ត្រូវធានាឲ្យបានថាពួកគេបានទទួលឧបករណ៍ការពារផ្ទាល់ខ្លួនសមស្រប

    건설 현장에 근로자를 투입시킬 때 작업에 적합한 개인보호구를 지급·착용토록 조치

# ឧបករណ៍ការពារ

## 보호구

2018-교육미디어-377

### តើ "ឧបករណ៍ការពារ" គឺជាអ្វី? '보호구'란?

- ឧបករណ៍ការពារគឺជាឧបករណ៍ដែលគេប្រើសម្រាប់ការពារគ្រោះថ្នាក់ការងារដោយការកាត់បន្ថយ ឬលុបបំបាត់កត្តាបង្កទុក្ខទោស ឬគ្រោះថ្នាក់ តាមរយៈការពាក់លើផ្នែកណាមួយនៃរាងកាយ ឬពាក់លើរាងកាយទាំងមូល ឬដោយការកាត់បន្ថយកម្រិត និងបរិមាណនៃការខូចខាត។ ឧបករណ៍ការពាររួមមាន មួកសុវត្ថិភាព ស្បែកជើងសុវត្ថិភាព វ៉ែនតាសុវត្ថិភាព ស្រោមដៃសុវត្ថិភាព និងខ្សែក្រវ៉ាត់សុវត្ថិភាព។
  근로자의 신체 일부 또는 전체에 착용해 외부의 유해·위험요인을 차단하거나 그 영향을 감소시켜 산업재해를 예방하거나 피해의 정도와 크기를 줄여주는 기구로써 안전모, 안전화, 보안경, 안전장갑 그리고 안전대 등이 있다.

### ព្រំដែននៃការប្រើប្រាស់ឧបករណ៍ការពារ 보호구의 제한적 사용

- អនុវត្តវិធានការចាំបាច់ដូចជា ការកែលម្អរគ្រឿងបរិក្ខារដើម្បីការពារកម្មករពីការងារដែលមានហានិភ័យ និងគ្រោះថ្នាក់ ទោះបីជាពេលពួកគេមិនប្រើឧបករណ៍ការពារក៏ដោយ
  보호구를 사용하지 아니하더라도 근로자가 유해·위험 작업으로부터 보호를 받을 수 있도록 설비개선 등 필요 조치 실시
- ប្រើប្រាស់ឧបករណ៍ការពារពេលធ្វើការ តែក្នុងករណីដែលពិបាកអនុវត្តវិធានការខាងលើ
  상기의 조치를 하기 어려운 경우에만 제한적으로 해당 작업에 맞는 보호구를 사용




### ប្រអប់ត្រួតពិនិត្យ | រចនាសម្ព័ន្ធជណ្តើរ (រួមទាំងជណ្តើរបណ្តោះអាសន្ន)

Check Box | 보호구의 선택 시 고려사항

- ជ្រើសរើសឧបករណ៍ការពារត្រឹមត្រូវដែលសមស្របសម្រាប់កត្តាហានិភ័យ និងគ្រោះថ្នាក់នីមួយៗ ដោយធ្វើការពិនិត្យវត្តមានរបស់ឧស្ម័ន ធូលី សារធាតុគីមី កាំរស្មីគ្រោះថ្នាក់ អគ្គិសនីស្តាទិច អគ្គិសនីតង់ស្យុងខ្ពស់ កង្វះអុកស៊ីសែន សីតុណ្ហភាពខ្ពស់ ។ល។
  가스, 분진, 화학물질, 소음, 유해광선, 정전기, 고압전기, 산소 결핍, 고열 등의 유무를 조사하여 해당 유해·위험요소에 맞는 보호구를 선택
- កំណត់កម្រិតនៃកត្តាហានិភ័យ និងគ្រោះថ្នាក់
  유해·위험요소의 수준이 얼마나 되는지를 파악
- ជ្រើសរើសឧបករណ៍ការពារដែលត្រឹមត្រូវ កំណត់ភាពញឹកញាប់ក្នុងការប្រើប្រាស់វា
  올바른 보호구 선택을 위해서는 보호구를 얼마나 자주 사용하는지를 파악
- កំណត់លំដាប់ការពារអាស្រ័យតាមមជ្ឈដ្ឋានធ្វើការនៃកន្លែងដែលត្រូវប្រើ
  사용 장소의 작업환경에 따라 보호범위를 설정

#### រាងកាយ និងហានិភ័យ 신체와 위험요소





OPEN 출처표시 공공누리 공공저작물 자유이용허락

## ប្រភេទឧបករណ៍ការពារ 보호구의 종류

| ឧបករណ៍ការពារ<br>보호구 | | ប្រភេទការងារ<br>작업명 |
|---|---|---|
| មួកសុវត្ថិភាព<br>안전모 |  | • ការងារដែលមានហានិភ័យពីការខ្ទាត ឬធ្លាក់វត្ថុនានា ឬហានិភ័យពីការធ្លាក់កម្មករ<br>물체가 떨어지거나 날아올 위험 또는 근로자가 떨어질 위험이 있는 작업 |
| ខ្សែក្រវ៉ាត់សុវត្ថិភាព<br>안전대 |  | • ការងារនៅកន្លែងដែលមានហានីភ័យនៃការធ្លាក់ពីទីដែលមានកម្ពស់ ឬជម្រៅលើសពី 2 m<br>높이, 깊이 2미터 이상의 떨어질 위험이 있는 장소에서 하는 작업 |
| ស្បែកជើងសុវត្ថិភាព<br>안전화 |  | • ការងារងាយគ្រោះថ្នាក់ដោយមានហានិភ័យពីការប៉ះទង្គិចនឹងវត្ថុធ្លាក់ពីលើ ការកៀបជាប់នៅក្នុងវត្ថុអ្វីមួយ ឬការឆក់ខ្សែភ្លើង<br>떨어지는 물체에 맞거나 물체에 끼이거나 감전, 정전기 대전 위험이 있는 작업 |
| វ៉ែនតាសុវត្ថិភាព<br>보안경 |  | • ការងារដែលអាចធ្វើឲ្យវត្ថុនានាពាយប៉ាយ<br>물체가 흩날릴 위험이 있는 작업 |
| របាំងការពារមុខ<br>보안면 |  | • ការងារដែលអាចធ្វើឲ្យផ្កាភ្លើង ឬវត្ថុអ្វីមួយខ្ទាតចេញក្នុងពេលផ្សារ<br>용접 시 불꽃이나 물체가 흩날릴 위험이 있는 작업 |
| ឧបករណ៍ការពារដោយអ៊ីសូឡង់<br>절연용 보호구 |  | • ការងារដែលមានហានិភ័យពីការឆក់ខ្សែភ្លើង<br>감전 위험이 있는 작업<br>• ការងារអគ្គិសនីនៅកន្លែងបិទជិតដូចជា រូង និងបន្ទប់ក្រោមដីដែលត្រូវប៉ះពាល់នឹងខ្សែភ្លើងដែលមានចរន្ត<br>노출 충전부가 있는 맨홀, 지하실 등 밀폐공간에서의 전기작업<br>• ការងារអគ្គិសនី ដែលប្រើប្រាស់ឧបករណ៍ចល័ត<br>이동 및 휴대장비 등을 사용하는 전기작업<br>• ការងារអគ្គិសនីនៅលើ ឬនៅជិតកន្លែងដែលមានខ្សែកាបអគ្គិសនីធ្លាក់<br>정전전로 또는 그 인근에서의 전기작업<br>• បញ្ជា ឬកាន់យានជំនិះ ឬម៉ាស៊ីននៅជិតខ្សែកាបអគ្គិសនីដែលមានចរន្ត<br>충전전로 인근에서의 차량, 기계장치의 운전·조작작업 |
| សំលៀកបំពាក់ការពារកំដៅ<br>방열복 |  | • ការងារដែលមានហានិភ័យពីការរលាកដោយសារសីតុណ្ហភាពខ្ពស់ ឬការអស់កម្លាំងដោយសារកំដៅ<br>고열에 의한 화상이나 열피로 위험이 있는 작업<br>• ការកាន់របស់ក្តៅច្រើនពេក ឬការធ្វើការនៅកន្លែងក្តៅខ្លាំងពេក<br>다량의 고열 물체를 취급하거나 매우 더운 장소에서 하는 작업 |
| ម៉ាសការពារធូលី<br>방진마스크 |  | • ការងារលើកដាក់ទំនិញនៅកន្លែងដូចជា ផែដែលមានធូលីកកើតយ៉ាងច្រើន<br>분진이 심하게 발생하는 선창 등의 하역작업 |
| សំលៀកបំពាក់ ស្បែកជើងកវែង ស្រោមដៃ និងមួករដូវរងា<br>방한모·방한복<br>방한화·방한장갑 |  | • ការងារលើកដាក់នៅកន្លែងបង្កកត្រីនៅសីតុណ្ហភាពដក 18° C<br>섭씨 영하 18도 이하인 급냉동 어창에서의 하역작업<br>• ការងារកាន់របស់ត្រជាក់ច្រើន ឬនៅក្នុងកន្លែងដែលត្រជាក់ខ្លាំង<br>다량의 저온물체를 취급하거나 현저히 추운 장소에서 하는 작업 |

# កត្តាហានិភ័យនិងវិធានការសុវត្ថិភាពសម្រាប់ម៉ាស៊ីនសំណល់ឧស្សាហកម្ម

## 건물 등의 청소 시 작업 안전

2018-교육미디어-378

### ⚠ ករណីគ្រោះថ្នាក់ 재해사례



• គ្រោះថ្នាក់កើតឡើងនៅពេលកម្មកររអិល ឬដួលនៅពេលសម្អាតអគារ
건물 등의 청소작업 중 작업자가 헛디디거나 미끄러져 넘어지는 사고 발생

## ប្រភេទចម្បងនៃការងារ និងកត្តាហានិភ័យ/គ្រោះថ្នាក់
주요 작업 유형 및 유해·위험요인

**ការងារសម្អាតកម្រាល និងផ្លូវដើរក្នុងអគារ**
복도 및 바닥 청소작업

- ដួលនៅពេលសម្អាតកម្រាលរអិល
  미끄러운 바닥 청소작업 시 넘어짐
- គ្មានបទពិសោធន៍ក្នុងការប្រើប្រាស់ឧបករណ៍សម្អាត
  청소용 기계기구 사용 미숙
- ជញ្ជូនសម្ភារៈធ្ងន់ៗពេកដោយប្រើដៃ
  무리한 중량물 인력 운반
- ហានិភ័យពីការខូចសុខភាពនៅពេលប្រើសារធាតុគីមីដូចជាសាប៊ូសម្រាប់សម្អាតជាដើម
  청소용 세제 등 화학물질 사용 시 건강장애 발생 위험

**ការសម្អាតពិដាន ជញ្ជាំង គ្រោង និងបង្អួច**
천장·벽·구조물 및 유리창 청소작업

- រលំកៅអី ឬជណ្តើរក្នុងពេលធ្វើការ
  의자 및 사다리 작업 시 떨어짐
- ការជញ្ជូនដោយប្រើកម្លាំងលើកដាក់ធ្ងន់ធ្ងរ
  무리한 중량물 인력 운반
- ធ្លាក់នៅពេលសម្អាតជញ្ជាំងខាងក្រៅដោយប្រើខ្សែពួរតែមួយ
  외벽, 외줄 청소작업 시 떨어짐

**ការងារសម្អាតជណ្តើរ**
계단 청소작업

- ធ្លាក់ចុះពីជណ្តើររអិល
  미끄러운 계단에서 넘어짐
- ហានិភ័យពីការមានបញ្ហាសាច់ដុំ និងឆ្អឹង ដោយសារការសម្អាតច្រើនម៉ោងដោយប្រើឥរិយាបថមិនសុខស្រួល
  불편한 자세로 장시간 청소작업 시 근골격계질환 발생 위험

**ការងារសម្អាតបង្គន់**
화장실 청소작업

- ដួលលើកម្រាលរអិល
  미끄러운 바닥에서 넘어짐
- បុក ឬកៀបជាប់ទ្វារ
  문 등에 충돌 또는 끼임
- ហានិភ័យពីការខូចសុខភាពនៅពេលប្រើសារធាតុគីមីដូចជាសាប៊ូសម្រាប់សម្អាតជាដើម
  청소용 세제 등 화학물질 사용 시 건강장애 발생 위험

**ការជូតផ្ទៃឲ្យរលោង**
왁스 작업

- ដួលលើកម្រាលរអិល
  미끄러운 바닥에서 넘어짐
- ឆក់ខ្សែភ្លើង ដែលបណ្តាលមកពីម៉ាស៊ីនសម្អាត
  청소용 기계기구에 의한 감전
- ហានិភ័យពីការខូចសុខភាពនៅពេលប្រើសារធាតុគីមីដូចជាសាប៊ូសម្រាប់សម្អាតជាដើម
  청소용 세제 등 화학물질 사용 시 건강장애 발생 위험

## បទបញ្ញត្តិ និងវិធានការសុវត្ថិភាពសម្រាប់កម្មករសម្អាតនៅក្នុងអគារ
건물 등 청소 작업 근로자 안전대책 및 수칙

### នៅពេលសម្អាតអគារ 건물 청소 시

- ផ្តល់ឧបករណ៍ការពារចាំបាច់ដល់កម្មករ ហើយត្រូវធានាឲ្យបានថាកម្មករពាក់ពួកវា
  필요한 보호구 지급·착용 확인
- ណែនាំកម្មករឲ្យកាន់បង្កាន់ដៃនៅពេលឡើងចុះជណ្តើរ
  계단을 오르내릴 때 손잡이를 잡고 다니도록 지도
- ត្រួតពិនិត្យឲ្យប្រាកដថា ជណ្តើរមិនមានបាក់ និងបានអនុវត្តវិធានការការពាររអិល
  계단에 파손 부위가 없고 미끄럼방지 조치를 했는지 점검
- ធានាឲ្យបានថា កម្មករមិនពាក់ស្បែកជើងផ្ទាត់/ស៊ក ឬដើរចុះឡើងដោយសង្កត់កែងជើងស្បែកជើងចុះក្រោម
  슬리퍼를 착용하거나 신발을 꺾어 신지 않는지 확인
- រៀបចំវត្ថុធាតុ និងឧបករណ៍ធ្វើការជាប្រចាំ ដើម្បីធ្វើឲ្យច្រកផ្លូវមានសុវត្ថិភាព
  작업 도구나 자재를 수시로 정리하여 통로를 확보하는지 점검
- ធានាឲ្យបានថា ជណ្តើរមិនរលំ ឬរអិល ហើយកម្មករធ្វើការដោយមានគ្នាពីរៗនាក់
  사다리가 넘어지거나 미끄러지지 않도록 조치하고 2인1조로 작업하는지 확인
- ត្រួតពិនិត្យឲ្យប្រាកដថា ម៉ាស៊ីនបូមធូលី ឬម៉ាស៊ីនរំលីងត្រូវបានភ្ជាប់ឌុយ និងព្រីដែលមិនជ្រាបទឹក
  청소기나 연마기를 방수형 콘센트 및 플러그에 연결해 사용하는지 점검
- ត្រួតពិនិត្យឲ្យប្រាកដថា ខ្សែភ្លើងចល័តត្រូវបានដំឡើងកុងតាក់ផ្តាច់ភ្លើងឆ្លងទៅដី និងបានភ្ជាប់ខ្សែដីរួចហើយ
  이동전선에 누전차단기를 설치하고 접지를 시키는지 점검
- ត្រួតពិនិត្យឲ្យប្រាកដថា រទេះសម្រាប់សម្អាត បានដំឡើងហ្វ្រាំងរួចហើយ
  청소용구 운반카트에 브레이크 설치확인
- កំណត់ថាតើអ្នកគ្រប់គ្រង (អ្នកបើកបរ) ដូចជាអ្នកខាត់ អ្នករំលីង ឬអ្នកជូត ត្រូវបានតែងតាំងហើយឬនៅ
  광택기, 연마기, 청소차 등의 관리자(운전자)를 지정했는지 파악
- ត្រួតពិនិត្យមើលថាតើកម្មករបានបញ្ចេញបញ្ចូលខ្យល់គ្រប់គ្រាន់ឬទេ ពេលប្រើសារធាតុធ្វើឲ្យរលាកស្បែកដូចជា សារធាតុការពារមិនឲ្យជាប់ ឬថ្នាំខាត់
  박리제, 광택제 등 피부자극성 물질 사용 중 충분히 환기를 하는지 점검
- ត្រូវដាក់សញ្ញាប្រយ័ត្នរអិល នៅពេលលាង ឬជូតកម្រាលឲ្យរលោង
  물청소, 왁스 작업 시 미끄럼주의 표지 설치 확인
- ជូតទឹក ឬសាប៊ូដែលរអិលលើកម្រាលឲ្យបានស្អាតល្អក្រោយពេលសម្អាត
  청소 후 바닥에 미끄러운 세제나 물기를 깨끗이 제거
- ធានាឲ្យបានថា បុគ្គលិកសម្អាតត្រួតពិនិត្យនៅនឹងកន្លែងតាមកាលកំណត់
  청소책임자의 주기적인 현장 점검
- ណែនាំកម្មករមិនត្រូវធ្វើការដោយរក្សាឥរិយាបថដដែលក្នុងរយៈពេលយូរទេ ហើយត្រូវឧស្សាហ៍សម្រាក
  같은 자세로 오랫동안 작업하지 않고 틈틈이 짧은 휴식을 취하도록 지도
- នៅពេលលើករបស់ធ្ងន់ ចូរពិនិត្យមើលឲ្យប្រាកដថា កម្មករធ្វើការដោយមានគ្នាពីរៗនាក់ ឬប្រើរទេះរុញដៃ
  중량물 취급 시 2인1조로 작업하거나 대차를 사용하는지 점검
- ណែនាំកម្មករឲ្យសន្ធឹងដៃជើងខ្លួនប្រាណជាទៀងទាត់នៅពេលធ្វើការ
  작업 중 수시로 스트레칭을 하도록 지도



[ត្រូវធ្វើការបញ្ចេញបញ្ចូលខ្យល់ឲ្យបានគ្រប់គ្រាន់ពេលប្រើសារធាតុធ្វើឲ្យរលាកស្បែក]
[ 피부자극성물질 사용 시 충분히 환기 실시 ]




[ដាក់សញ្ញាប្រយ័ត្នរអិលនៅពេលលាងសម្អាត ឬជូតផ្ទៃកម្រាលឲ្យរលោង]
[물청소, 왁스 작업 시 미끄럼주의 표지 설치]